ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

**សុន្ទរកថា**
**ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**
**ថ្លែងក្នុងឱកាសប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៥**
**នៃប្រតិបត្តិការធនាគារកណ្តាល**
នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០១៤

**សូមគោរព ៖**

**- គណៈអធិបតី**
**- ឯកឧត្តម រដ្ឋមន្ត្រី**
**- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអតិបរមា ដែលបានចូលរួមក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៥ នៃប្រតិបត្តិការធនាគារកណ្តាល ។ ពិធីនេះរៀបចំឡើងដើម្បីអបអរសាទរសមិទ្ធផលការងារនិងតួនាទីធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលនៃប្រទេសកម្ពុជា បានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ក្នុងរយៈពេល ៣៥ឆ្នាំកន្លងមក ។ ខ្ញុំសូមថ្លែងអំណរគុណជាអនេកចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញាទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីនេះ ។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរយ៉ាងខ្លាំងចំពោះអតីតទេសាភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ ដែលបានរួមចំណែកអភិវឌ្ឍធនាគារជាតិនៃកម្ពុជាកន្លងមក ។ បច្ចុប្បន្ន វិស័យធនាគារមានការអភិវឌ្ឍរីកចម្រើនគួរឱ្យកត់សម្គាល់ និងបានដើរតួនាទីស្នូលក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ហើយមានលក្ខណៈសមាហរណកម្មទៅនឹងតំបន់និងពិភពលោកថែមទៀត ។ ទន្ទឹមពេលនេះ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះគ្រប់ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាល អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ ក្នុងការរួមចំណែកអភិវឌ្ឍវិស័យធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើន ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!

មុននឹងឈានចូលដំណាក់កាលអភិវឌ្ឍរីកចម្រើនដូចសព្វថ្ងៃនេះ វិស័យធនាគារ និងប្រព័ន្ធរូបិយវត្ថុកម្ពុជាយើង បានឆ្លងកាត់ដំណើរដ៏វែងឆ្ងាយពោរពេញដោយឧបសគ្គនិង ការផ្លាស់ប្តូរជាច្រើនដំណាក់កាល ។ ដើម្បីជ្រាបពីការអភិវឌ្ឍរីកចម្រើនទាំងនេះ ខ្ញុំសូម ជម្រាបជូនពីប្រវត្តិ តួនាទី និងប្រតិបត្តិការធនាគារកណ្តាលនៃធនាគារជាតិនៃកម្ពុជា ដែល បានរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម រយៈពេល ៣៥ឆ្នាំកន្លងមកនេះ ។

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៧៩ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ក៏បានបង្កើត **"ធនាគារជាតិនៃប្រជាជនកម្ពុជា"** ជាធនាគារកណ្តាលនៃប្រទេសកម្ពុជាឡើងវិញ តាមអនុក្រឹត្យ លេខ១១២១ អ.ន.ក្រ ។ បន្ទាប់ពីបង្កើតធនាគារជាតិនៃប្រជាជនកម្ពុជារួចមក ប្រាក់រៀលថ្មី ត្រូវបានបោះផ្សាយ និងដាក់ឱ្យធ្វើចរាចរឡើងវិញ នៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ដើម្បី ធ្វើជាមធ្យោបាយដោះដូរ ជាខ្នាតតម្លៃ និងជាឧបករណ៍សន្សំរបស់ប្រជាជន ។ នេះ គឺជា ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយយ៉ាងសំខាន់ ក្រោយថ្ងៃមហាជ័យជម្នះ ៧ មករា និងជាជោគជ័យ របស់រដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយសេដ្ឋកិច្ចផងដែរ ។ នាពេលនោះ ប្រទេស កម្ពុជាមានប្រព័ន្ធធនាគារមួយថ្នាក់ ពោលគឺធនាគារកណ្តាលមានភារកិច្ចបោះផ្សាយរូបិយវត្ថុ ជាតិ បេឡាថវិការដ្ឋ ផ្តល់ឥណទាន និងទទួលប្រាក់បញ្ញើ ។

ការបង្កើតធនាគារកណ្តាលរបស់ប្រទេសមួយ និងការដាក់រូបិយវត្ថុជាតិឱ្យចរាចរ ឡើងវិញ គឺជាផ្នែកមួយនៃការកសាងអធិបតេយ្យភាព និងអំណាចខាងសេដ្ឋកិច្ចរបស់រដ្ឋ ។ មានតែរដ្ឋទេដែលមានសិទ្ធិបោះពុម្ពលុយ ។ លុយ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ និងប្រជាជន នៃប្រទេសទាំងមូល ។

ចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៨៩ ប្រទេសកម្ពុជាស្ថិតនៅក្នុងដំណាក់កាលមានសន្តិភាព ផង និងមានសង្គ្រាមផង ។ នៅឆ្នាំ១៩៨៩ សភាពការណ៍សេដ្ឋកិច្ចកម្ពុជាមានការវិវត្តប្រែប្រួល ជាវិជ្ជមានគួរឱ្យកត់សម្គាល់ ដោយរដ្ឋាភិបាលបានធ្វើកំណែទម្រង់សេដ្ឋកិច្ច ពីរបបសេដ្ឋកិច្ច ផែនការប្រមូលផ្តុំទៅជារបបសេដ្ឋកិច្ចទីផ្សារ ។ ទន្ទឹមនោះ ប្រព័ន្ធធនាគារក៏ត្រូវបានចាប់ផ្តើម ធ្វើកំណែទម្រង់ផងដែរ ស្របតាមយន្តការសេដ្ឋកិច្ចទីផ្សារ ។ តាមច្បាប់ស្តីពីគ្រឹះស្ថានរូបិយវត្ថុ នៅឆ្នាំ១៩៩២ ធនាគារជាតិនៃប្រជាជនកម្ពុជាត្រូវបានប្តូរឈ្មោះទៅជា **"ធនាគារជាតិនៃកម្ពុជា"** និងបានប្រែក្លាយប្រព័ន្ធធនាគារជាពីរថ្នាក់ រហូតដល់សព្វថ្ងៃនេះ ។

នៅថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារ ជាតិនៃកម្ពុជាត្រូវបានអនុម័តដោយរដ្ឋសភា ដើម្បីពង្រឹងប្រសិទ្ធភាពប្រតិបត្តិការ និងពង្រឹង តួនាទីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការដឹកនាំគោលនយោបាយរូបិយវត្ថុ ។ ច្បាប់នេះ បាន កំណត់មុខងារ-ភារកិច្ចរបស់ធនាគារជាតិនៃកម្ពុជា ជាធនាគារកណ្តាលនៃប្រទេស និងជា អាជ្ញាធរអាណាព្យាបាលលើប្រព័ន្ធធនាគារទាំងមូល ហើយមានបេសកកម្មចម្បង គឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ ដើម្បីគាំទ្រស្ថិរភាពម៉ាក្រូ សេដ្ឋកិច្ច និងរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រកបដោយចីរភាព ។

នៅឆ្នាំ១៩៩៩ ច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុត្រូវបានប្រកាសឱ្យប្រើប្រាស់ធ្វើជាមូលដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងសកម្មភាពរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុដែលធ្វើប្រតិបត្តិការនៅកម្ពុជា និងជាចំណុចចាប់ផ្តើមនៃការធ្វើកំណែទម្រង់ធនាគារនៅកម្ពុជា ។ នៅឆ្នាំ២០០០ អនុវត្តតាមស្មារតីនៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ យើងបានចាប់ផ្តើមអនុវត្តកម្មវិធីកំណែទម្រង់គ្រឹះស្ថានធនាគារ ដើម្បីពង្រឹងសុខភាព និងជំនឿទុកចិត្តសាធារណជនទូទៅមកលើប្រព័ន្ធធនាគារនៅកម្ពុជា ។ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុទាំងអស់ ត្រូវបានតម្រូវឱ្យបំពេញដើមទុនរបស់ខ្លួនឱ្យបានគ្រប់គ្រាន់តាមកម្រិតដើមទុនអប្បបរមាដែលបានកំណត់ និងតម្រូវឱ្យគ្រឹះស្ថានទាំងនោះរៀបចំនិងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដើម្បីកាត់បន្ថយបាននូវហានិភ័យផ្សេងៗ ។

នៅឆ្នាំ២០០១ ដើម្បីបន្តពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ឱ្យមានដំណើរការទៅដោយរលូន មានសុវត្ថិភាព និងមានកម្រិតសមាហរណកម្មប្រហាក់ប្រហែលនឹងប្រទេសក្នុងតំបន់ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តចក្ខុវិស័យ និងផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០១-២០១០ ដើម្បីកំណត់ផែនការយុទ្ធសាស្ត្រតាមលំដាប់លំដោយអាទិភាពក្នុងការពង្រឹងនិងអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ។

ដោយយល់ឃើញពីសារៈសំខាន់នៃឯកសារយុទ្ធសាស្ត្រនេះ ទើបរាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្មឱ្យទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥ ដើម្បីរំកិលទៅអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយនូវកម្មវិធីផ្សេងៗទៀត ។ បន្ទាប់មក ឯកសារយុទ្ធសាស្ត្រនេះត្រូវបានរាជរដ្ឋាភិបាលធ្វើបច្ចុប្បន្នកម្មឱ្យទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី!**

បច្ចុប្បន្ន វិស័យធនាគារនៅកម្ពុជាមានការរីកចម្រើនទាំងផ្នែកវិសាលភាព និងទំហំសកម្មភាព ។ ផ្នែកវិសាលភាព មានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុជាច្រើន មានបណ្តាញសាខានៅតាមរាជធានី-ខេត្តទូទាំងប្រទេស ហើយបានផ្តល់សេវាធនាគារនិងហិរញ្ញវត្ថុតាំងពីទីក្រុងរហូតដល់ជនបទ ។ ចំណែកឯ ទំហំសកម្មភាពវិញ អាចឆ្លុះបញ្ចាំងបានតាមរយៈការកើនឡើងឥតឈប់ឈរនៃទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារ ប្រាក់បញ្ញើរបស់សាធារណជន និងឥណទានចំពោះវិស័យឯកជន ។ គិតត្រឹមខែសីហា ឆ្នាំ២០១៤នេះ ទ្រព្យសកម្មរបស់វិស័យធនាគារបានកើនឡើងដល់ប្រមាណ ១៥ពាន់លានដុល្លារអាមេរិក ពោលគឺកើនឡើងប្រមាណ ៧២ដង ធៀបនឹង ២០ឆ្នាំមុន ហើយទំហំប្រាក់បញ្ញើបានកើនឡើងដល់ប្រមាណ ៩ពាន់លានដុល្លារអាមេរិក ស្មើនឹង ១២៨ដង និងទំហំឥណទានបានកើនឡើងដល់ប្រមាណ ៨ពាន់លានដុល្លារអាមេរិក ស្មើនឹង ១៣៦ដង ។ ទ្រព្យសកម្មក្នុងវិស័យធនាគារស្មើនឹងប្រមាណ ៩៣% នៃផ.ស.ស ហើយប្រាក់បញ្ញើស្មើនឹង ៥២% និងឥណទានស្មើនឹង ៤៧% ។

ទន្ទឹមនឹងការរីកចម្រើននៃវិស័យធនាគារ វិស័យមីក្រូហិរញ្ញវត្ថុក៏មានការរីកចម្រើនយ៉ាងខ្លាំងផងដែរ ។ នៅឆ្នាំ២០០៥ អង្គការសហប្រជាជាតិបានប្រកាសយកឆ្នាំ២០០៥ ជាឆ្នាំមីក្រូហិរញ្ញវត្ថុពិភពលោក ហើយនៅឆ្នាំ២០០៦ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសប្រសិទ្ធនាមយកឆ្នាំ២០០៦ ជាឆ្នាំមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ។ បច្ចុប្បន្ន វិស័យនេះមានការរីកចម្រើននិងមានភាពរឹងមាំ ទាំងរចនាសម្ព័ន្ធនិងទំហំប្រតិបត្តិការរហូតដល់ជនបទ ។ ប្រជាជនដែលទទួលបានសេវាមីក្រូហិរញ្ញវត្ថុបានកើនឡើងជាលំដាប់ ។ ភាពជឿនលឿននេះបញ្ជាក់ឱ្យឃើញថា ប្រជាពលរដ្ឋកម្ពុជាកាន់តែមានជំនឿទុកចិត្តនិងយល់ដឹងពីសារៈសំខាន់នៃសេវាមីក្រូហិរញ្ញវត្ថុ និងវប្បធម៌ឥណទាន ។

រីឯ ប្រព័ន្ធទូទាត់មានលក្ខណៈកាន់តែទំនើបទាន់សម័យដូចបណ្តាប្រទេសក្នុងតំបន់ដែរ ដោយគ្រឹះស្ថានធនាគារទាំងអស់ខិតខំពង្រីកបណ្តាញសេវា និងផលិតផលហិរញ្ញវត្ថុរបស់ខ្លួន ដូចជា ការកើនឡើងនៃសេវាដកប្រាក់ដោយស្វ័យប្រវត្តិតាមម៉ាស៊ីន ATM ដោយប្រើប័ណ្ណឥណពន្ធនិងប័ណ្ណឥណទាន សេវាទូទាត់ដោយប្រើម៉ាស៊ីនឆូតកាត (POS) និងសេវាធនាគារតាមទូរសព្ទចល័តជាដើម ។ គិតត្រឹមខែសីហា ឆ្នាំ២០១៤ ប្រព័ន្ធធនាគារកម្ពុជាមានម៉ាស៊ីន ATM ចំនួន ៨៨៦កន្លែង នៅទូទាំងប្រទេស ធៀបនឹងឆ្នាំ២០០៥ មានតែ ១ប៉ុណ្ណោះ ប័ណ្ណឥណពន្ធមានចំនួន ១,២៣លាន ប័ណ្ណឥណទានមានចំនួន ៣ម៉ឺន ម៉ាស៊ីនឆូតកាតចំនួន ៥,៦១៣ និងប៉ុស្តិ៍សេវាផ្ទេរប្រាក់ Wing មានភ្នាក់ងារចំនួន ១,៩២៧កន្លែង និងមានចំនួនអ្នកប្រើប្រាស់ប្រមាណ ៥៣ម៉ឺននាក់ ។

ភាពល្អប្រសើរនៃស្ថានភាពសេដ្ឋកិច្ចគួបផ្សំនឹងកិច្ចសហប្រតិបត្តិការនេះ បានជួយពង្រឹងសមត្ថភាពស្ថាប័នក្នុងស្រុក និងបានទាក់ទាញវិនិយោគបរទេសមកកម្ពុជា ជាពិសេសធនាគារនៃបណ្តាប្រទេសជឿនលឿននានា ឱ្យចូលមកវិនិយោគនៅកម្ពុជា ហើយបានធ្វើឱ្យវិស័យធនាគារនៅកម្ពុជាកាន់តែសមាហរណកម្មខ្ពស់ទៅកាន់តំបន់និងពិភពលោក ។

រួមមក រយៈពេល ៣៥ឆ្នាំនេះ ប្រទេសកម្ពុជាក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាបច្ចុប្បន្ន មានការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យធនាគារនៅកម្ពុជាមានការរីកចម្រើនជាលំដាប់ ហើយត្រូវបានចាត់ទុកថា បានដើរតួនាទីស្នូលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ឆ្ពោះទៅរកការកាត់បន្ថយភាពក្រីក្រ និងបានលើកកម្ពស់ជីវភាពប្រជាជន ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ចំពោះស្ថានភាពម៉ាក្រូសេដ្ឋកិច្ចមានលក្ខណៈល្អប្រសើរ និងបានគាំទ្រដល់កំណើនសេដ្ឋកិច្ចជាតិ ។ អត្រាប្តូរប្រាក់ និងតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក មានស្ថិរភាពជាទូទៅក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ។ ទន្ទឹមនេះ អត្រាអតិផរណាបានប្រែប្រួលក្នុងកម្រិតទាបអាចគ្រប់គ្រងបាន តាមរយៈការអនុវត្តនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន ។

ទុនបម្រុងអន្តរជាតិដុលបានកើនឡើងក្នុងល្បឿនប្រមាណ ១០% ជារៀងរាល់ឆ្នាំ ។ ជាក់ស្តែង ក្នុងរយៈពេល ១៥ឆ្នាំចុងក្រោយនេះ កំណើនសេដ្ឋកិច្ចបានកើនឡើងលើសពីការរំពឹងទុក ដោយមានអត្រាពីរខ្ទង់ ចាប់ពីឆ្នាំ២០០៤-២០០៨ ។

**ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី !**

សរុបមក សមិទ្ធផលសេដ្ឋកិច្ចនិងសង្គមក្នុងរយៈពេល ៣៥ឆ្នាំកន្លងមកនេះ កើតឡើង ដោយសារនយោបាយឈ្នះ-ឈ្នះរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី បានធ្វើឱ្យប្រទេស យើងមានសុខសន្តិភាពនិងស្ថិរភាពនយោបាយ រួមទាំងការអនុវត្តគោលនយោបាយបើក ចំហចំពោះអន្តរជាតិរបស់រាជរដ្ឋាភិបាល ក្នុងនោះ សមិទ្ធផលនានា ដែលធនាគារជាតិនៃ កម្ពុជាសម្រេចបានកន្លងមកនេះ ក៏កើតឡើងដោយសារតែមានការគាំទ្រពីកម្លាំងសរុប គ្រប់ផ្នែកទាំងអស់ និងការកំណត់ដំណាក់កាលអនុវត្តតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ ហិរញ្ញវត្ថុរយៈពេលវែងរបស់រាជរដ្ឋាភិបាលប្រកបដោយប្រសិទ្ធភាព ។ ហើយសមិទ្ធផល ទាំងនេះ ក៏មិនអាចកាត់ផ្តាច់បានពីការខិតខំប្រឹងប្រែងបំពេញការងារ ប្រកបដោយស្មារតី ទទួលខុសត្រូវខ្ពស់របស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងការចូលរួមសហការល្អពី ក្រសួង-ស្ថាប័ន និងអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងៗទៀតបានឡើយ ។

ដើម្បីបន្តការអភិវឌ្ឍប្រទេសជាតិមាតុភូមិយើងឱ្យកាន់តែរីកចម្រើន និងមានលក្ខណៈ សមាហរណកម្មនៅក្នុងតំបន់និងពិភពលោក សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រ ជាអាទិភាពថា កម្ពុជាយើងត្រូវតែ ៖ *ទី១)* បន្តពង្រឹងនិងអភិវឌ្ឍធនធានមនុស្សលើគ្រប់ផ្នែក គ្រប់ថ្នាក់ និងគ្រប់វិស័យ និង *ទី២)* អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមជារូបវន្ត មាន ទឹក ភ្លើង និងផ្លូវ ដែលជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិបន្ថែមទៀត ។

អនុវត្តតាមស្មារតីនេះ ជាទិសដៅរយៈពេលមធ្យម និងវែង ខាងមុខ ធនាគារជាតិ នៃកម្ពុជាក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិនឹងត្រូវ ៖

១- បន្តអភិវឌ្ឍធនធានមនុស្សរបស់ធនាគារជាតិនៃកម្ពុជាឱ្យស្របតាមតម្រូវការ សេដ្ឋកិច្ចជាតិ និងការប្រែប្រួលនៃនិម្មាបនកម្មហិរញ្ញវត្ថុអន្តរជាតិក្នុងពេលបច្ចុប្បន្ន និងទៅអនាគត

២- បន្តពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារ ឱ្យមានសុខភាពរឹងមាំ មានសុវត្ថិភាពនិង មានលក្ខណៈសមាហរណកម្មទៅក្នុងតំបន់និងពិភពលោក ស្របតាមយុទ្ធសាស្ត្រ អភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរយៈពេលវែងរបស់រដ្ឋាភិបាល និង

៣- ខិតខំបន្តអនុវត្តគោលនយោបាយរូបិយវត្ថុដោយប្រុងប្រយ័ត្ននិងទន់ភ្លន់ សំដៅ រក្សាស្ថិរភាពថ្លៃ និងគាំទ្រស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

**"យើងត្រូវរួមគ្នាដើម្បីអភិវឌ្ឍ ការអភិវឌ្ឍសម្រាប់យើងទាំងអស់គ្នា"**

ដើម្បីជ្រាបពីសមិទ្ធផលសេដ្ឋកិច្ចនិងសង្គមឱ្យកាន់តែច្បាស់បន្ថែមទៀត ខ្ញុំសូមអញ្ជើញ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញាទាំងអស់ ស្តាប់បទឧទ្ទេសនាមស្តីពី វិថីរបស់កម្ពុជា ឆ្នាំ១៩៩៨-ឆ្នាំ២០១៣ ដោយ លោក ហ្សង់ដានីញ៉ែល ហ្គារឌែរ អតីតទីប្រឹក្សាពាណិជ្ជកម្មនិងសេដ្ឋកិច្ចប្រចាំស្ថានទូតបារាំងនៅកម្ពុជា និងសម្របសម្រួលដោយ ឯកឧត្តម ស៊ុំ សន្និសិទ្ធ អគ្គលេខាធិការធនាគារជាតិនៃកម្ពុជា ។

មុននឹងបញ្ចប់ ខ្ញុំសូមលើជូនសុភាសិតមួយឃ្លារបស់លោក Victor Hugo ដែលជាអ្នកប្រាជ្ញជនជាតិបារាំងដ៏ល្បីល្បាញមួយរូប បានពោលថា "La vieillesse bien comprise est l'âge de l'espérance" មានន័យថា វ័យចំណាស់ដែលល្អ ដែលយល់ដឹងបានល្អ មេរៀនប្រវត្តិសាស្ត្រដែលសិក្សាស្វែងយល់បានល្អ បទពិសោធន៍អតីតកាលដែលបានយកមកវិភាគវែកញែកបានល្អ គឺជាមូលដ្ឋានគ្រឹះយ៉ាងរឹងមាំសម្រាប់ជាសេចក្តីសង្ឃឹមនាពេលអនាគត ។ ៣៥ឆ្នាំ នៃការបង្កើតឡើងវិញប្រតិបត្តិការធនាគារកណ្តាលនេះ មិនត្រឹមតែជាដំណើរដ៏វែងប៉ុណ្ណោះទេ តែជាវិញ្ញាសារឆ្លងកាត់មួយដែលពោរពេញទៅដោយចក្ខុវិស័យច្បាស់លាស់ និងត្រឹមត្រូវ ទើបយើងអាចសម្រេចបានសមិទ្ធផលជាច្រើន គួរជាទីមោទនៈដូចសព្វថ្ងៃនេះ ហើយក៏ជាមូលដ្ឋានគ្រឹះដែលធានាបាននូវការអភិវឌ្ឍរីកចម្រើនរបស់ប្រព័ន្ធធនាគារនៅកម្ពុជាឱ្យស្របតាមនិន្នាការនៃការវិវត្តរីកចម្រើនរបស់សេដ្ឋកិច្ចជាតិ តំបន់ និងសកលលោកនាពេលអនាគតថែមទៀតផង ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងភ្ញៀវកិត្តិយសដែលមានវត្តមានក្នុងអង្គពិធីនេះ និងសូមជូនពរឱ្យមានសុខភាពល្អ និងទទួលបានជ័យជម្នះគ្រប់ភារកិច្ច ។

ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៥ នៃប្រតិបត្តិការធនាគារកណ្តាលរបស់យើង ខ្ញុំសូមប្រកាសបើកអង្គសិក្ខាសាលាស្តីពីវិថីរបស់កម្ពុជាចាប់ពីពេលនេះតទៅ ។

**សូមអរគុណ**!